# វគ្គ

# ស្ម័គ្រចិត្តគ្រួសាររបស់មិត្ត

«ភីរៈ! យើងមកភ្នំពេញបានបួនថ្ងៃហើយ! ទើបតែជួសជុលកុំព្យូទ័ររួចទើបបានសរសេរទៅឯងកើតហើយហ្នឹងកំពុងធ្វើអី Friend?! អ្វីៗចំពោះឯងល្អដែរទេ? ក្នុងផ្ទះអាពេជ្រ មានបងស្រីធំរបស់គេ និងកូនប្រុសម្នាក់៧ឆ្នាំ! ត្រូវហើយ យើងទុកគេជាក្មួយរបស់យើង! គ្រប់គ្នាហៅយើងថាពេជ្រ! ហើយឯងដឹងទេ ប្អូនៗគេទាំងពីរនាក់ ប្រុសបង១៩ឆ្នាំ ហើយគេក៏ឡូយសង្ហា ឈ្មោះប៊ី! ចំណែកស្រីពៅវិញគេស្អាតខ្លាំងណាស់! គេឈ្មោះពណ្ណរី គេរៀននៅវិចិត្រសិល្បៈ!»

ស្នូរអ្វីមួយលាន់មកកាត់ផ្តាច់អារម្មណ៍នាង.....

សូរសព្ទមិនខ្លាំង.... តែនាងត្រូវតែក្រោកទៅព្រោះជាសំឡេងយំ....

«ភីរៈ! យើងដូចជាឮប្អូនយើងយំ! មិនបានឆាតទៀតទេ! ចាំជួបគ្នាទៀត!»

.....ជាមួយភាពព្រួយបារម្ភអាថ៌កំបាំង នាងក្រោកចោលកុំព្យូទ័រហើយ ឆ្ពោះទៅកាន់បន្ទប់តូចខាងក្រោយដែលជាកម្មសិទ្ធិរបស់ពណ្ណរី។

ប៊ីនៅក្រៅបន្ទប់ដៃចុចទូរសព្ទ មុខខឹងសម្បារ..... ឯបងស្រីធំរុញទ្វារដើរចេញមកដោយទឹកមុខខូចចិត្ត.... ក្មេងប្រុស៧ឆ្នាំ ជាកូនគាត់នៅរេរាក្បែរនោះទាំងដៃកាន់ក្តារឈ្នួន....

ស៊ីវីដឹងថាអ្វីមួយបានកើតឡើងជាចំណោទ សូម្បីតែនាងទើបតែចូលមកក្នុងគ្រួសារនេះបានប៉ុន្មានថ្ងៃ... នាងស្រដីសួរទៅកាន់ប៊ី៖

«ពណ្ណរីមានរឿងអី?!»

ប៊ីមិនឆ្លើយ តែដៃគេស៊ីញ៉ូរបៀបថា គេកំពុងរវល់ស្តាប់ទូរសព្ទ។

ស៊ីវីរវេក្នែកទៅរកបងស្រីធំជាបន្ទាន់។

គាត់សម្លឹងមុខនាងដោយស្រងូត ហើយដកដង្ហើមធំ លូកដៃមកទាញនាងចាកចេញឆ្ងាយពីបន្ទប់នោះ។

មកដល់ផ្ទះបាយ គាត់ខ្សឹបៗតិចៗ៖

«ពណ្ណរីត្រូវគេជម្រុះចោលហើយ វាមិនបានឡើងឆាកប្រលងទេ!»

«តួឯករាងកាយហ្នឹងអ្វីបង?!»

«ហ្នឹងហើយ កម្មវិធីតួឯកឆោមគន់!!»

«ហេតុអី? រូបរាងពណ្ណរី គឺសមឥតទាស់នឹងកម្មវិធីនេះទៅហើយ?»

«ឯងមិនដឹងទេ! ពុករលួយ! កាលពីម្សិលម៉្ងៃ អ្នកទទួលដឹម៉ង់ម្នាក់ខ្សឹបវាថា ត្រូវបង់២០០ដុល្លារ បើចង់ជាប់ជម្រុះឡើងវគ្គទីមួយ!..... តែយើងមានលុយពីណាមក! ព្រឹកមិញ ពណ្ណរីទៅមើលឈ្មោះ គេទម្លាក់ដឹម៉ង់វាចោលហើយ! សូម្បីតែបានឡើងឆាកម្តង ក៏គេអត់ទុកពេលឱ្យវាផង!»

អំពើ ពុករលួយដ៏រ៉ាំរ៉ៃក្នុងវិស័យសិល្បៈ នាងធ្លាប់តែឮ តែមិននឹកស្មានថាជាក់ស្តែងថ្នាក់នេះឡើយ។ នាងដឹងហើយថា ហេតុអីបានជាពណ្ណរីឈឺចាប់ដល់ថ្នាក់យំ? ពីព្រោះថាភាពអយុត្តិធម៌នេះគ្មានអ្នកណាម្នាក់អាចទទួលយកវាបាន ឡើយ។ ស្រីស្អាតយ៉ាងនេះមិនអាចមានឱកាសសូម្បីតែឡើងវគ្គប្រកួតដំបូង?

នាងបែរក្រោយតម្រង់ទៅរកបន្ទប់តូច ប៉ុន្តែត្រូវបានបងស្រីមេម៉ាយទាញដៃឃាត់មកវិញ.... ។ ពេលនាងសម្លឹងគាត់ដោយពិបាកចិត្ត.... គាត់និយាយប្រាប់ខ្សឹបៗ៖

«ពេជ្រ! ស្រីពៅឆេវឆាវណាស់ ពេលដែលខូចចិត្ត! កុំទាន់ចូលទៅ!»

ស៊ីវីកាន់តែក្តុកក្តួលចិត្ត។

មនុស្សម្នាក់កំពុងតូចចិត្ត ស្អិតទ្រូង ហើយមិនព្រមទទួលយកសូម្បីតែការលួងលោមរបស់អ្នកណាម្នាក់ តើអាចស្តារស្ថានការណ៍បានដោយវិធីណា?

សំឡេងប៊ីនិយាយទូរសព្ទលាន់មកកាត់ផ្តាច់ចង្វាក់បេះដូងក្តុកក្តួលរបស់បងស្រីថ្លែងក្លាយ។

«អ្ហែ! អ្ហែងមានស្គាល់ណាគេនៅ DM Empire អត់អ្ហា? អយុត្តិធម៌ដល់ហើយអ្ហា ពណ្ណរីដាក់ពាក្យទៅ Program តួឯកឆោមគន់នោះ គេទារ២០០! ប្អូនគ្នាអត់លុយឱ្យ គេដក CV វាគ្រវាត់ចោលតែហ្មង អ្ហា! ពួកម៉ាកវានៅសាលាវិចិត្ររូបអន់ចាញ់វាគគោក តែគេទៅជាជាប់បានឡើងឆាក វាមិនអស់ចិត្តសោះអ្ហែចង់តវ៉ាដល់ហើយ!»

គេនិយាយចុះឡើងច្រើនដងណាស់ទម្រាំបិទទូរសព្ទដោយទឹកមុខអស់សង្ឃឹម។ ក្រឡេកមកប៉ះបងស្រីដែលទើបវិលមកពីមណ្ឌលក្មេងកំព្រា។ គេគ្រវីក្បាលជំនួសចម្លើយថា គ្មានផ្លូវស្រោចស្រង់ឱកាសឱ្យប្អូនស្រីពៅឡើយ។

.....ប៊ីដើរហួស ទៅ.... ទុកឱ្យស៊ីវីនៅឈរពិបាកចិត្ត..... ចង់ដឹងអន្ទះសាថា ពៅពណ្ណរីនៅខាងក្នុងកំពុងកើតទុកកម្រិតណា ប៉ុន្តែនាងមិនហ៊ានរុញទ្វារចូលទៅ ព្រោះតែបម្រាមរបស់បងស្រីធំរួចទៅហើ

យ។

ស្រីតូចឱនមករកក្បួយប្រុស ហើយក្រសោបគេក្នុងរង្វង់ដៃ....

«តោះ ទៅលេងនៅក្រៅវិញណ៎ា!»

ដៃកាន់របស់ម្យ៉ាង។

វាជាកម្មសិទ្ធិរបស់នាង.... ត្រូវហើយ វាជាសន្លឹកនាមប័ណ្ណដែលធ្វើឱ្យនាងនឹកឃើញដល់គេម្នាក់....

«ទៅភ្នំពេញខលមកបង! បងប្រហែលជួយរកការងារឱ្យធ្វើបាន!»

ត្រូវហើយ.... គេជាសិល្បករ.... គេអាចថាស្គាល់អ្នកណាម្នាក់នៅក្រុមហ៊ុនមួយដែលប៊ីបាននិយាយមុន នេះ.... ដូច្នេះហើយ នាងពិនិត្យលេខទូរសព្ទរបស់គេ....

«អាឡូបង? បងឯងចាំខ្ញុំបានអត់? ខ្ញុំស៊ីរីនៅសៀមរាបណា! នៅមណ្ឌលក្មេងកំព្រានោះអី?!»

«....ចាំតើ!»

គេឆ្លើយមកវិញខ្លី ហើយស្រទន់។

នាងនឹកតែម្យ៉ាងថា នាងអាចនឹងធ្វើអ្វីមួយជួយដល់មនុស្សក្នុងគ្រួសារនេះ។ បុរសម្នាក់នោះពុំមែនជាប្រធានបទអ្វីធំដុំសម្រាប់នាងស្រាប់ទៅ ហើយ ប៉ុន្តែខាងគេវិញប្រហែលជាករណីផ្សេង....

នាងម៉េចនឹងដឹងបានទៅថា យប់នោះសៀវភៅបេះដូងរបស់គេចាប់ផ្តើមកត់ត្រាសាជាថ្មី.....

....ថ្ងៃ នេះខ្ញុំបានចាប់ផ្តើមយល់ពីអ្វីដែលកំពុងកើតមាន ជាអារម្មណ៍ក្នុងការលង់ស្រលាញ់អ្នកណាម្នាក់ គឺអារម្មណ៍ពិសេសមួយ បន្ទាប់ពីពេលដែលត្រូវបែកគ្នា ហើយយល់ថាបាត់អស់ព្រលឹងពាក់កណ្តាលពីខ្លួនយើង.... ចំណែកពេលគេបង្ហាញវត្តមានមកវិញ យើងស្រាប់តែច្របូកច្របល់ព្រួយបារម្ភជាខ្លាំងដោយគ្មានហេតុគ្មានផល  គិតផ្តេសផ្តាសប្រៀបបីដូចទើបតែពេញកំលោះអាយុ១៨ឆ្នាំ ឬជាតាចាស់អាយុ៧០ឆ្នាំ ភ័យខ្លាចថា បើខ្ញុំត្រូវស្លាប់ដោយប្រការណាមួយមុនថ្ងៃស្អែកមកដល់ទាំងខកខាន ឃើញនាងម្តងទៀត ខ្ញុំមិនមានឱកាសឱ្យនាងឃើញពីភាពដ៏អស្ចារ្យរបស់ខ្ញុំក្នុងនាមជា បុរសម្នាក់ ហើយខ្លាចថា ខ្ញុំគ្មានសំណាងក្នុងការមានស្រីដ៏ល្អម្នាក់ដូចនាងមកឱបក្នុង ទ្រូង។

.................................

សាយណ្ហសម័យនារាជធានីភ្នំពេញ

«សុំទោសបានទេដែលឱ្យបងចាំ?!»

គេសម្លឹងនាងដោយខ្សែភ្នែកផ្អែមល្ហែម។ បុរសនេះពុំចាំបាច់ឆ្លើយអ្វីក៏តួស្រីដឹងរួចហើយថា គេងណាទៅខឹងនាង?

ទឹកមុខតក់ក្រហល់របស់ស្រីតូចប្តូរសន្សឹមៗមកជាស៊ីជម្ពូ ហើយនាងគេចចេញពីការពាក់ព័ន្ធភ្នែកជាមួយគេ តែបេះដូងនាងនៅបន្តលោត។

«ហើយចុះគេនេះកំពុងគិតអី ហេតុអ្វីមើលមកយើងចម្លែកៗម៉េះ?»

នាងអង្គុយចុះ ពេលដៃអ្នករត់តុទាញកៅអីឱ្យដោយឱនលំទោន។

ស៊ីវីរវៃភ្នែកពិនិត្យជុំវិញហាង បន្ទាប់មកចាប់អារម្មណ៍ថាអ្វីៗនៅទីនេះថ្លៃថ្នូរគួរឱ្យបារម្ភពីរឿងចំណាយ។

«ញ៉ាំអី?!»

សំឡេងគេលាន់មក ទាញនាងឱ្យងាកមកវិញយ៉ាងរហ័ស។

«ចាស៎ …… គឺ… ហើយ….. ហើយចុះបងឯងញ៉ាំអី?!»

គេញញឹម ហើយសម្លឹងនាងដូចខ្លាចថាលែងបានសម្លឹង មាត់គេឆ្លើយៈ

«ម៉េច? ចង់ញ៉ាំកែវមួយពីរនាក់?!»

«មិនដែលទេ! គ្រាន់តែគេមិនធ្លាប់មកហាងល្អយ៉ាងនេះ ក៏មិនដឹងត្រូវហៅអីញ៉ាំ!!! ដែលចង្រៃគឺបងឯងដឹងហើយ ប្រឹងមកឌឺគេទៀត?!»

«ឃើញមុខយើងទ្រាំមិនឌឺ វាមិនសប្បាយ!»

ស្រីតូចលូកដៃស្ទាបថ្ពាល់ក្រោមកែវភ្នែកស្នេហារបស់ភាគីខាងប្រុស។

«មុខខ្ញុំ….. មុខខ្ញុំយ៉ាងម៉េច!!?»

«អាក្រក់!» គេឆ្លើយភ្លាមជាមួយបបូរមាត់ញញឹមប្រកបដោយអំណាចទាក់ទាញក្នុងភាពជា បុរសក្នុងពេញលក្ខណៈ។ ឯនាងជ្រប់មុខខ្មាស ហើយជឿសម្តីគេភ្លាម។

មាត់ស្រីល្អពោលរអ៊ូៈ

«ខ្ញុំម៉េចស្អាតដូចសង្សារបងឯង?!»

គេសើចរលាក់ស្មា ឯនាងបន្តខឹង ងាកទៅនិយាយនឹងអ្នករត់តុដែលឈរចម្ងាយប្រមាណពីរម៉ែត្ររង់ចាំបម្រើ។

«បង!….. អ្ហែបង!»

គេរត់មកលំទោន ហើយត្រៀមកត់៖

«កុម្ម៉ង់អីទាន?»

«មានរបស់អីដែលលេបហើយកាលណា ក្លាយជាស្អាតដូចទេពធីតាអត់?!»

អ្នករត់តុធ្វើមុខញឹមៗសម្លឹងប្រុសស្រីទាំងទ្វេដោយអស់សំណើច។

ភាគីបុរសមិចភ្នែកដាក់អ្នករត់តុហើយស្ដារស្ថានការណ៍៖

«អូនយករបស់ណាផ្អែមៗត្រជាក់ៗមក ព្រោះពួកកូនក្មេងចូលចិត្តតែរបស់ផ្អែមទេ!»

អ្នករត់តុញញឹម លួចមើលមុខនាង ហើយឱនកាយគោរពមុនចាកចេញ។ ស្រីស្អាតលួចញញឹម តែមិនព្រមក្រឡេកមើលគេឡើយ ព្រោះទទួលអារម្មណ៍ថា គេកំពុងផ្ដោតភ្នែកសម្លឹងនាង។ នាងបួញមាត់រអ៊ូ៖

«បងឯងចាស់ប៉ុណ្ណាទៅ? ចង់ធ្វើចាស់ម៉េះ?!»

អ្នកបម្រើត្រឡប់មក វិញជាមួយពែងភេសជ្ជៈក្នុងដៃក្ដៅហ៊ុយជះក្លិនកាហ្វេឈ្ងុយមុត។ ភេសជ្ជៈរបស់គេធ្វើឱ្យនាងតាមសម្លឹងភ្លឹកហើយបង្អាប់ភ្លាម៖

«បងឯងចាស់មែនហើយ ញ៉ាំឡើងរបស់ក្ដៅ!»

«ចង់ភ្លក់ដែរអត់អ៊ីចឹង?!»

«អត់ទេ!»

តែគេហុចមកឱ្យនាងនៅចំពីមុខ នាងគ្រវីក្បាល៖

«ប្រាប់ហើយថាអត់ទេ!»

«បងចង់ឱ្យយើងភ្លក់!»

«ស្អីទៅ? ហើយហេតុអី?!»

«ញ៉ាំសិនចាំសួរ!»

នាងងើបមុខមើលទៅគេដែលកំពុងចចេស។ គេមិចភ្នែកជាសញ្ញាថា គេមិនបញ្ឈប់ការបង្ខំនេះទេ។ នាងកាត់សាញ៖

«បានតើ! វាមិនដែលស្លាប់ទេ!»

នាងក្រេបយករសជាតិកាហ្វេដែលស្រាល ហើយក្រអូបប្រហើរ សាបឈឹងគ្មានទេរសជាតិ។ រួចរាល់ ស្រីតូចរុញទៅឱ្យម្ចាស់ប្រុសវិញទាំងស្រដីបង្អាប់៖

«គ្មានរសជាតិទេ!»

«សាកមើលម្តងទៀតទៅ!»

គេរុញមកទៀត នាងក៏ឃើញភាពមានៈនៅលើទឹកមុខគេទៀត ស៊ីវីក៏ភ្លក់សាជាថ្មី ហើយរុញសងវិញ៖

«ដដែល!»

នាងនិយាយទាំងលើកចិញ្ចើមឆ្ងល់ថា គេនេះចម្លែកម្ល៉េះ តែហេតុអីនាងខ្លួនឯងរឹតតែចម្លែកទៀត ព្រោះថាដូចជាចូលចិត្តគេ ហើយមានអារម្មណ៍ស្និទ្ធតាំងពីទើបតែជួបគ្នាបានបីដង?

រឹតតែ វរទៀតគឺ ពេលនេះគេឱនសម្លឹងស្នាមក្រែមពណ៌ចុងឈូករបស់នាងដែលប្រឡាក់លើ គែមពែងកាហ្វេ។ រង្វង់មុខគេឱន ប៉ុន្តែគឺភ្នែកគេងើយមករកនាង។ មាត់គេញញឹមក្នុងពេលនាងអៀនខ្មាសបំផុត។ នាងគិតថា គេនឹងឌឺនាងមិនខានដែលលាបក្រែមពេលមកជួបគេ រហូតដល់ជ្រុលប្រឡាក់កែវរបស់គេទៀត។ ប៉ុន្តែគេមិនឌឺ មិននិយាយអ្វីដូចនាងគិតឯណា អ្នកណាស្មានដឹងទៅ ក្នុងភាពស្ងៀមស្ងាត់ គេឱនទៅដាក់បបូរមាត់ត្រួតពីលើស្នាមក្រែមរបស់នាង ហើយក្រេបភេសជ្ជៈ។

បេះដូងនាងហាក់គាំងពិបាកដកដែលទទួលអារម្មណ៍ ថា គេនេះមិនមែនធម្មតាដូចនាងគិត គឺគេកំពុងប្រាប់នាងថា គេចៃចង់នាងដោយបើកចំហ។ ដែលចម្លែកជាងនេះទៅទៀត គឺពេលដែលគេលេបត្របាក់ស្នាមបបូរមាត់នាងឱ្យនាងឃើញចំពោះមុខ វាហាក់បីដូចជាបង្ហាញអ្វីមួយជាសម្ងាត់មកក្នុងបេះដូងនាងថា គេកំពុងតែឈានហួសព្រំដែនក្នុងការគោរពមនុស្សស្រីក្រមុំម្នាក់ ហើយជាក្រមុំជនបទដូចជានាង។

«ដែលលោកធ្វើគឃ្លើន ដូច្នេះលោកកំពុងគិតទៅដល់រឿងអ្វី? អាក្រក់ណាស់! ទុកចិត្តលោកខុសទាំងស្រុង!» នាងគិតម្នាក់ឯងជាមួយទឹកមុខស្លេកស្លាំង ហើយចាប់ផ្តើមក្រោក។

ជាការពិតគឺ នាងនឹងទៅទាំងគ្មានពាក្យថាលា រហូតដល់នាងដឹងថា គេលូកដៃមកចាប់ដៃនាងជាប់។ នាងខ្មាសជំនួសឱ្យភាពជាព្រានរបស់គេ ទើបនិយាយញ័រៗថាឱ្យគេដោយមិនងាកសម្លឹងផង៖

«បងឯងដឹងអត់ ខ្ញុំខ្មាសគេ!»

នាងនៅស្ងៀមមិនឮគេឆ្លើយ ក៏ច្បូតដៃគេទម្លាក់ចេញតែច្បូតមិនរបើក នាងនិយាយទៀត៖

«បងឯងលែងដៃខ្ញុំ!»

គេបង្អង់ដៃស្រាលជាងមុនតែមិនលែងសោះ។ សំឡេងគេហើរមកលួងនាង៖

«ស្រទន់!»

«កុំហៅខ្ញុំអ៊ីចឹង ខ្ញុំមិនមែនឈ្មោះអ៊ីចឹងទេ!»

«យើងជាអ្នកណាត់បងមក!»

នាងតវ៉ាភ្លាមពេលមានអារម្មណ៍ថាគេកំពុងបន្ទោសនាង៖

«គឺខ្ញុំមានការ.....មិនមែន......!»

«មិនមែនអីទៅ?!»

សំឡេងគេស្លូតហើយស្រាល ធ្វើឱ្យនាងគិតឡើងវិញថា តើខ្លួនឯងច្របូកច្របល់ពេកឆេវឆាវពេកទេ ដឹងដែលប្រញាប់វាយតម្លៃគេ?

ស្រីស្អាត ងាកទៅសម្លឹងគេដោយកែវភ្នែកបារម្ភ។ បុរសនេះនៅតែមានស្នាមញញឹមជានិច្ច ជាស្នាមញញឹមនឹងនរក្នុងអាកប្បកិរិយាថ្លៃថ្នូរដ៏មានឥទ្ធិពល របស់គេ។

នាងទីរទើរមិនដឹងខ្លួនឯងកំពុងខឹងគេ ឬមួយកំពុងតែរងសម្ពាធដោយចង់គេចចេញពីភាពដ៏ទាក់ទាញរបស់គេទៅ។

នាងអង្គុយចុះមកវិញសន្សឹម ហើយងក់ក្បាល៖

«បាន! បំភ្លេចចោល ព្រោះបងឯងធ្លាប់ជួយពួកខ្ញុំ! តែឈប់ណ៎ា កុំធ្វើអីដែលប្លែកៗអ៊ីចឹងពេក!»

«ប្លែកៗម៉េចទៅ?!»

គេឱណាស់ គេចង់ឱ្យនាងនឹកឃើញរឿងបបូរមាត់នោះមួយជីវិតហើយមើលទៅ?

នាងជ្រប់មុខក្រញូវ គេស្រាប់តែហុចពែងនោះមកសាជាថ្មី។

«អីទៀតហើយ?!»

«ញ៉ាំម្តងទៀតទៅ!!»

«ហេតុអី? ដែលមាត់បងឯងហ្នឹង?!»

«ក្រែងមិញក្លាហានណាស់ អួតថាវាមិនដែលស្លាប់អ្វី?!»

នាងទីទើរ ហើយបន្តបដិសេធ៖

«ខ្ញុំមានរឿងអីត្រូវធ្វើតាមបងឯង!»

«ព្រោះស្រទន់ត្រូវតែសាក!»

គេចចេសដាក់ឈ្មោះថ្មីឱ្យនាង ហើយហៅនាងដោយសំឡេងថ្នាក់ថ្នម ធ្វើឱ្យនាងងើបមុខសម្លឹងគេសន្សឹមៗ។ នាងនឹកដល់សម្តីខ្លួនឯង៖

«គេសង្ហាដូច ហួត យុត្តនា បេះបិទ!»

នាងដៀងភ្នែកមករកស្នាមខ្ទួចរបស់គេនិងបបូរមាត់គេដែលបានលេប ត្របាក់ស្នាមក្រែមរបស់នាង ស្ទេហានេះឆាប់ពេកហើយ! នាងលួចគិតទាំងបេះដូងកក់ក្ដៅ ព្រោះដៃគេហុចរបស់មកមានសញ្ញាថា បើនាងមិនទទួល គេនៅរង់ចាំជានិច្ច។

ស្រីស្អាតចងចិញ្ចើមរអ៊ូ៖

«បងឯងចម្លែកៗ!»

«ហើយគួរឱ្យស្រលាញ់អត់?!»

«អ៊ែក!» នាងពេបមាត់ឌឺ។

«ញ៉ាំម្ដងទៀតទៅ! តិចថាលេបបីលើក ភ្លេចវាលែងបានណា!»

«ផ្លូងជំងឺពីបងឯងមិនគិត?!»

គេផ្លាស់ទឹកមុខ ហាក់ស្រពន់ចិត្តដែលនាងយកសុខភាពគេមកមើលស្រាល។ គេត្រឹមថ្លោះទឹកមុខ ប៉ុណ្ណឹង នាងស្រាប់តែអាណិតចិត្តគេបាត់ទៅហើយ?

នាងសម្លឹងពែងកាហ្វេ ហើយនិយាយលក្ខខណ្ឌ៖

«តែម្ដងនេះទៀតទេណ៎ា យើងចូលដល់សាច់រឿងហ្មងទៅ! ឈប់លេងណ៎ា!»

នាងទទួលកាហ្វេមកក្រេបក្រោមកែវភ្នែកស្រទោរស្រទន់របស់គេ។

--------------------------------

រសជាតិកាហ្វេលើកទីបីនេះនៅតែ ស្រាលជាងហាងកាហ្វេដែលមណ្ឌលក្មេងកំព្រារបស់នាងដាក់លក់ សម្រាប់ ជនបរទេស។ តែនាងមិនចង់រិះគន់គេទៀតទេ ព្រោះខ្លាចបន្ដឌឺដងគ្នាវែងឆ្ងាយ នាងដាក់កែវ ទៅលើតុវិញ ហើយសួរខ្សឹបៗដោយសម្លឹងមុខគេ៖

«បងឯងជាអ្នកសិល្បៈនៅភ្នំពេញយូរហើយ ស្គាល់ DM Empire ទេ?!»

គេជ្រួញចិញ្ចើមហាក់ភ្ញាក់ផ្អើលនឹងសំណួរ តែប្ដូរជាលើកកាហ្វេមកលេបបន្តពីនាង។ នាងតាមទន្ទឹង ពាក្យឆ្លើយតបរបស់គេ ឃើញគេសម្លឹងនាងមិនមាត់នាងក៏និយាយទៀត៖

«ខ្ញុំចង់និយាយថា បងឯងធ្លាប់ឮពីក្រុមហ៊ុននេះទេ? ហើយមានស្គាល់អ្នកណានៅទីនោះដែរ?!»

កែវភេសជ្ជៈនាងត្រូវបានបញ្ជូនមកដល់ គេក៏និយាយបង្វែរនាង៖

«ញ៉ាំទឹករបស់យើងសិនទៅ!»

នាងប្រាស់ប្រាល់តវ៉ា៖
«ឈប់បញ្ឆោខ្ញុំទៅ! ហើយប្រាប់មកបងឯង ស្គាល់អត់ ក្រែងបងឯងអ្នកសិល្បៈអ្វី?!»
«DM Empire ល្បីយ៉ាងនេះ អ្នកភ្នំពេញណាអត់ស្គាល់កើតទៅ ក្មេងល្ងង់?»
គេសម្លុតជាមួយសំឡេងស្រាលៗរបស់គេធ្វើឱ្យនាងមិនខឹងបែរជាអរ។ នាងញញឹមស្រស់បញ្ចេញធ្មេញសត្រឹម ហើយឱនកាន់តែកៀកនឹងគេ ដោយនិយាយខ្សឹបដាក់គេ៖
«បងឯងជួយខ្ញុំផងណ៎ា! ខ្ញុំចង់ជួបបុគ្គលិករបស់គេ អ្នកដែលកាន់កម្មវិធី តួឯកឆោមគន់!»
គេសម្លឹងរាងកាយនាងយ៉ាងរហ័ស ហើយសម្លឹងសាច់ម៉ត់រលោងនៅក្រោមបំពង់កជ្រួលច្របល់របស់នាង។
សំឡេងគេលាន់មកមួយៗ ប៉ុន្តែមិនស្រណុកចិត្តអ្នកស្តាប់ប៉ុន្មានទេ៖
«នៅសុខៗមិនចង់ ចង់ទៅដើរម៉ូដបង្ហាញរាងឱ្យពីណាមើល!?»
គេមិនត្រឹមស្គាល់ DM Empire ថែមទាំងស្គាល់ច្បាស់នូវកម្មវិធីដែលនាងកំពុងនិយាយ ដូច្នេះហើយដោយក្តីសង្ឃឹមនិងភាពត្រេកអរ នាងបានភ្លេចគិតពីការបន្ទោសមិនពេញចិត្តជាលើកដំបូងដែលគេបាន បញ្ចេញមក។
នាងនិយាយតឿនគេ៖
«ត្រូវហើយ! កម្មវិធីអ្នកបង្ហាញម៉ូដហ្នឹង! បងឯងមានស្គាល់អ្នកណាម្នាក់ទេដែលធ្វើការខាងហ្នឹង? ខ្ញុំត្រូវការជួបគេខ្លាំងណាស់! បងដឹងអត់? ប្អូនស្រីខ្ញុំ ពៅពណ្ណរី គេស្អាតខ្លាំងណាស់ គេខ្ពស់អស្ចារ្យណាស់ ឈរលើសខ្ញុំដល់ទៅកម្ពស់នេះ! បងដឹងទេ? ប៉ុន្តែគេមិនទាន់បានទាំងដើរនៅមុខគណៈកម្មការម្តងផង ក៏ត្រូវទម្លាក់ជម្រុះបាត់ទៅហើយ! គឺពុករលួយណា ពួកអ្នកទទួល CV អស់នោះ ទារប្អូនខ្ញុំដល់ទៅ២០០ដុល្លារ យើងគ្មានលុយច្រើនយ៉ាងណានេះឯណា! អ៊ីចឹងហើយ ពណ្ណរីត្រូវបាត់បង់ឱកាសតាំងពីថ្ងៃដំបូងតែម្តង បងគិតទៅមើលអយុត្តិធម៌ណាស់មែនទេ?»
គេនៅស្ងៀមរក់ចិត្តនឹង ភាពអន្ទះសានិយាយញាប់ស្មេររបស់នាង។ លុះនាងនិយាយចប់ ឃើញគេនៅស្ងៀមមិនឆ្លើយក៏បន្តទាំងស្រពោន៖
«បងឯងមិនស្គាល់គេទេមែនអត់?!»
គេអស់សំណើចស្រដីតបវិញដោយមិនដកភ្នែកចេញពីភាពអន្ទះសានៅលើវង់ភក្ត្ររបស់នាង៖
«តក់ក្រហល់ម៉េះ? គិតមុខក្រោយបន្តិចមើល! បើថាគេ ពុករលួយដូចដែលយើងថាមែន គេមានរឿង

អីព្រមជួបយើង? ហើយបើជួបអត់លុយឱ្យគេដដែល ទៅជួបធ្វើអី?»

នាងកាន់តែបង្ហាញការខកចិត្ត ហើយនិយាយសង៖

«ហោចណាស់.....ហោចណាស់ យើងអាចសួរនាំគេ....ក្រែង....ក្រែងយើងអាចពន្យល់គេឱ្យដូរចិត្តវិញ!»

គេសើចរលាកស្មា។

«បងសើចធ្វើអី? ចុះបើបងឯងមានមធ្យោបាយល្អជាងនេះ ម៉េចមិននិយាយមក!»

«គឺសើចយើងដែលរលះរលាំងមិនដឹងលិចមិនដឹងកើត! ទៅពន្យល់ឱ្យគេដូរចិត្តវិញអ៊ីចឹងអ្វេស៎?!»

នាងក្រញូវ មិនមែនខឹងគេគឺ ខឹងពីលទ្ធភាពរបស់ខ្លួនឯង។ ក្រោមពន្លឺភ្នែកស្រទោរស្រទន់របស់គេ នាងលើកភេសជ្ជៈរបស់ខ្លួនមក ក្រេបឱ្យអស់ពីកែវ ហើយទើបចចេសតវ៉ារអ៊ូបន្ត៖

«គ្រាន់ជាងនៅស្ងៀមមិនធ្វើអ្វីម្យ៉ាងសោះដែរ!»

គេញញឹមបង្ហាញស្នាមខួចដែលខាបយកបេះដូងនាងតាំងពីពេលជួបគ្នាជាលើកទីមួយ។ នាងងើបមុខមកប៉ះនឹងសម្រស់របស់គេ ក្រសែភ្នែកគេ ហើយសន្ទឹកបេះដូងនាងរើដោយការលោតរំជួល។

.....ហើយម៉េចក៏ស្នាមញញឹមគេដូចចង់លេបយកយើងទាំងមូលអ៊ីចឹង?

នាងឱនមុខវិញធ្វើជាចាប់នេះចាប់នោះ តែកន្ទុយភ្នែកមិនអាចបញ្ឆោបានទេ នាងនៅតែរេចុះឡើងលបមើលកាយវិការគេ។

«បងឯងមិនដែលឃើញស្រីស្អាតទេអ្ហេះ???!»

នាងនិយាយបន្លប់ ព្រោះគេមើលនាងនោះមើល មើលសឹងតែថាទោះនាងសុទិដ្ឋិប៉ុណ្ណាក៏ទ្រាំនឹងគេមើលនេះមិនបាន។

គេនៅតែមិនឆ្លើយ ហើយក៏មិនឈប់មើល នាងរអ៊ូបន្ថែម៖

«បើថាជួយមិនបានក៏ប្រាប់មកនៅ បន្លាយពេលនៅហ្នឹងហើយ?»

គេក្ដោបម្រាមដៃទាំងសងចូលគ្នា ហើយផ្ទឹបមករកបបូរមាត់ កុំឱ្យនាងឃើញទឹកមុខខ្លួន ដឹងចិត្តខ្លួនតែបេះដូងគេចាប់ផ្ដើមសាជាថ្មីនូវការពណ៌នាបន្តមិន ចេះនឿយណាយ....

«.....ខ្ញុំដឹងថានាងកំពុងជ្រួលចិត្ត..... ខ្ញុំដឹងពីភាពទាក់ទាញរបស់ខ្ញុំដែលកំពុងមានឥទ្ធិពលទៅលើនាងហើយនាងកំពុងគេចភ្នែកពីខ្ញុំ ព្រោះក្នុងប្រស្រីភ្នែកនាងមានរូបខ្ញុំ...

....កុំព្រួយអីស្រីតូចរបស់បង.... បងក៏មានអារម្មណ៍ដូចគ្នានេះ ហើយមុននិងក្រោយ អូនគឺជារបស់បង!»

នាងនៅធ្វើមុខម៉ក់ៗក្រោមខ្សែភ្នែកស្ងប់ស្ងួតរបស់គេ... ហើយនាងក៏គេចភ្នែកចេញទៀត....

«ចុះបើបងជួយយើងបាន?»

នាងបើកភ្នែកធំៗបន្ទាប់សម្ដីខ្លីៗស្រាលៗ តែប្រាកដប្រជារបស់គេ។

ស្រីតូចងើបមុខមកវិញ ហើយសេចក្ដីអំណរលេចចេញឡើងពីបេះដូងបង្ហាញមកតាមប្រស្រីភ្នែកស្រស់ ចិញ្ចាច និងល្អបរិសុទ្ធរបស់នាង។

«មែនអ្វី?!»

«បងមានលក្ខខណ្ឌ!»

គេនិយាយនេះ ព្រោះថាខ្លួនគេក៏មិនអាចទប់ចិត្តបន្លាយយូរទៀតដែរ។

នាងជ្រប់មុខពិបាកចិត្ត៖

«ខ្ញុំមានអីឱ្យបងឯងទៅ? គ្មានស្អីទាំងអស់! លុយក៏អត់ ស្អីក៏អត់!»

គេញញឹមពេលនាងស្រពោនចិត្ត។

នាងរអ៊ូមកបន្ថែមរង្វើរ៖

«ស្មានថាជួយដោយស្មោះ!»

«នៅភ្នំពេញនេះគ្មានអី Free ទេកូនក្មេង!»

នាងតវ៉ាភ្លាមមិនឱ្យបាត់មួយម៉ាត់៖

«នៅសៀមរាបក៏ដូចគ្នា! នៅឯណាក៏ដូចគ្នា គ្មានអ្វី Freeទេ តែ....ខ្ញុំ...ខ្ញុំស្មានតែបងឯង......!»

«ស្មានយ៉ាងម៉េច?!»

«ស្មានតែ.....អ្ហ៊ីយ ខ្ជិលនិយាយណាស់!»

«ស្មានថាមនុស្ស Free?!»

គេលលេងពេលដែលឃើញនាងធ្វើមុខខកចិត្ត អស់សង្ឃឹម។

នាងធ្វើស្រពោនងាកមុខចេញ បុរសក៏និយាយបង្ហើយ៖

«បើបងធ្វើឱ្យគេហៅប្អូនស្រីរបស់យើងឡើងឆាកប្រកួតបាន...... យើងត្រូវព្រមធ្វើរឿងបីយ៉ាងឱ្យបង!»

ឃ្លាដំបូងចាប់ចិត្តណាស់ គឺពណ្ណរីបានឡើងឆាក????

នាងត្រេកអរ ប៉ុន្តែឃ្លាទីពីរកំពុងធ្វើឱ្យនាងរារែក។

«បងឱ្យយើងជំពាក់សិន!»

គេនិយាយដោយមានជំនឿចិត្ត ហាក់ដូចជាអ្វីៗទាំងនោះនឹងក្លាយជាការពិត? តើប្អូននាងនឹងឡើងលើឆាកបាន?

ស្រីតូចមិនបន្លាយពេលក៏ឆ្លើយផ្ទួង៖

«គ្មានពីណាល្ងង់ទៅព្រមជាមួយបងឯងទេ!»

គេញាក់ស្មាធ្វើហី៖

«មានអី! យើងមានជម្រើសទេតើ! ជួយប្អូនឬក៏អត់?!»

នាងបូញមាត់ ភ្នែករេគិតចុះឡើងកំដរស្នាមញញឹមរបស់គេ ព្រោះគេដឹងថានាងនឹងមិនក្រោកទៅចោលគេឡើយ។

នាងនិយាយមកយឺតៗដូចកូនក្មេងទើបរៀនចេះនិយាយ៖

«ខ្ញុំព្រមតើ! តែ....បងឯងត្រូវសន្យា!»

គេប្រើកែវភ្នែកសែនឈ្លក់វង្វេងលង់នឹងចរិតក្មេងហួសមាឌរបស់នាង៖

«និយាយមកកូនក្មេង!»

សំឡេងគេគឺ ស្រទន់ជាងឈ្មោះដែលគេដាក់ឱ្យនាងទៀត ដូច្នេះហើយ នាងងើបមុខមកវិញញញឹមចិញ្ចាច ហើយនិយាយទាំងបេះដូងកក់ក្ដៅ៖

«១ អត់ធ្វើរឿងខុសច្បាប់! ២ អត់ធ្វើបាបអ្នកដទៃ ៣ អត់ធ្វើរឿង.....រឿង.....រឿងខុសប្រពៃណី!»

គេញញឹមក្ដាប់មាត់សែនពេញចិត្តនឹងភាពទៀងត្រង់របស់នាង។

គេលើកចិញ្ចើមផ្ទាន់សម្ដីចុងក្រោយរបស់នាង.... គឺឌឺនាង៖

«ខុសប្រពៃណីម៉េចទៅអូនៈ? ពន្យល់បានអត់?!»

នាងអៀន តែខំធ្វើជាមិនអៀន ហើយសម្លក់គេជាប់។

គេវិញអស់ពីក្ដាប់មាត់ ក៏សើចរលាក់បញ្ចេញសូរសំឡេងខឹកៗរង្គើអស់ស្មានិងដងខ្លួន។

ស្រីតូចនៅទ្រឹងនឹងស្នាមញញឹមរំជួយរាងកាយខ្ពស់ស្រោវស្រស់សង្ហារបស់គេ។

នាងនៅភាន់ភាំង បណ្ដោយឱ្យម្រាមចង្អុលដៃគេរុញមកប៉ះនឹងចុងច្រមុះខ្លួន ហើយគេនិយាយ៖

«ចាំសម្ដីខ្លួនណ៎ា!»

គេក្រោកឈរយឺតៗ ឯនាងងើបមុខយ៉ាងរហ័សតាមសម្លឹងគេ។ នាងចង់សួរគេ តែនិយាយមិនចេញ ព្រោះថារឿងជាច្រើនកំពុងទើរនៅចុងមាត់នាង។

បុរសឆ្លើយតបចំពោះកែវភ្នែកក្រឡង់ៗទាំងគូរបស់ស្រីតូច៖

«បងមានការត្រូវទៅ!»

នាងងក់ក្បាលតិចៗ ព្រោះនៅភាំងដែលគេនិយាយអ្វីៗលឿនៗ ហើយខ្លីៗយ៉ាងនេះពេក។ សំឡេងនរៈលាន់មកបង្ហើយ៖

«តែបងនឹងនឹកយើង!»

នាងងើបមុខមកវិញ ទាន់បានតែស្នាមញញឹមរបស់គេ ហើយនិងដំណើរខ្ពស់ស្រាវដែលឈានចេញទៅ។

គេនេះរហ័សរហួនហួសពេកហើយ គឺដូចជាពេលមួយដែលគេមកបរិច្ចាគលុយអ៊ីចឹងដែរ។

នាងនៅទ្រឹង ហើយខំរិះគិតត្រឡប់មកវិញនូវពាក្យពេចន៍ទាំងឡាយដែលគេនិងនាងទើបតែបានសាសងគ្នា។

ដៃមួយមកទម្លាក់លើស្មា ធ្វើឱ្យនាងស្រែកយ៉េទាំងភ្ញាក់ក្រញាង។

គឺភីរៈបង្ហាញខ្លួន.... គេលើកម្រាមមួយចង្អុលឃាត់កុំឱ្យនាងស្រែក...

«អ្វួយមកពញ្ញាក់ទៅកើត?»

នាងបន្លឺទាំងអំណរពេលបានឃើញមុខមិត្តដែលទើបតែបានជួបគ្នាវិញ។

ដៃបុរសក្មេងទាញកៅអីមកអង្គុយ ហើយលើកពែងកាហ្វេដែលសល់ពីអ្នកមុននេះមកពិនិត្យមើល។

«អ្នកណាអង្គុយនៅទីនេះមិញ?!»

នាងអេះអុញ ឯគេក៏មិនរង់ចាំចម្លើយ បែរជាឱនខិតមកខ្សឹបដាក់នាង៖

«ឯងដឹងទេ? មិញនេះ យើងជួបពីណានៅមុខហាង?»

នាងងាកទៅបក់ដៃហៅអ្នករត់តុមក ទាំងមាត់ឆ្លើយនឹងមិត្តភ័ក្តិបណ្ដើរ៖

«ពីណាទៅ?!»

ភីរៈនិយាយដោយញញឹមស្រស់៖

«នាយកផ្នែកពាណិជ្ជកម្មរបស់ DM Empire ដេត ភូមិន្ទ!»

«បង! យកទឹកដូចខ្ញុំមួយកែវទៀតមក ហើយគិតលុយហ្មងទៅណ៎ាបង!»

នាងនិយាយនឹងអ្នករត់តុដែលទើបចូលមកដល់ រួចហើយទើបនឹកឃើញភ្ញាក់ផ្អើលនឹងសម្ដីមិត្ត៖

«អ្ហះ? ភីរៈមិញនេះភីរៈឯងថាម៉េច?!»

«អឺ! គឺមេធំមួយរបស់ DM Empire! យើងជួបគេនៅក្រៅវ៉ី!»

នាងបើកភ្នែកធំៗផ្ទួនពាក្យសួរ៖

«អ្នកធំនៅ DM Empire អ្វី?!»

ភីរៈមិចភ្នែកទាំងញញឹម ឯនាងនៅចំហមាត់ផ្លុង ចំណែកអ្នករត់តុនិយាយមកពីក្រោយស្មានាង៖

«គឺលោកភូមិន្ទមិញនេះ! អឺនែ គាត់ចេញលុយរួចហើយ!»

នាងងើបមក ហើយបែរក្រោយវឹង ហើយបើកភ្នែកគ្រលួងសម្លឹងអ្នករត់តុ បន្ទាប់មក លើកម្រាមចង្អុលទៅកន្លែងដែលភីរៈអង្គុយ៖

«គេ....គេ.... គេដែលអង្គុយនៅទីនេះមិញហ្នឹងអ្វី?..... លោកភូមិន្ទអ្វី???»

អ្នករត់តុញញឹម ឯភីរៈបើកភ្នែកធំៗម្ដង៖

«អ្ហះ? គេអង្គុយនិយាយជាមួយឯងអ្វីស៊ីវី! កន្លែងនេះអ្វី?»

នាងធ្វើភ្លឹះៗសម្លឹងមិត្តរកនិយាយអ្វីមិនចេញ។

ដូច្នេះ អ្នករត់តុក៏ឆ្លើយជំនួស៖

«បាទ! អ្នកនិយាយជាមួយប្អូនស្រីហ្នឹងហើយ! នាយក DM គាត់ឈ្មោះដេត ភូមិន្ទ ជាភ្ញៀវប្រចាំនៅកន្លែងនេះ.....!»

ស្រីស្អាតវេភ្នែកមកសម្លឹងមិត្តសន្សឹមៗ ឯភីរៈក៏ធ្វើមុខឡេឡឡា ហើយញាក់ស្មាជាសញ្ញាថា «គ្មានយោបល់»។